**BMI0089**

# សម្ភាសន៍ជាមួយឈ្មោះ ខន ចំរើន ភេទប្រុស អាយុ៤៧ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“កុមារ”

## ស្រុកកំណើតនៅភូមិដូនទ្រី ឃុំជ្រៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

## រស់ភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៣៥:៣០

២១ទំព័រ

ប៊ុនថនៈ ជាដំបូងខ្ញុំចង់សួរឈ្មោះពូ ពូឈ្មោះអីដែរ?

ចំរើនៈ ខ្ញុំឈ្មោះខន ចំរើន ។

ប៊ុនថនៈ ខន ចំរើន?

ចំរើនៈ បាទ ។

ប៊ុនថនៈ ពូអាយុប៉ុន្មាន?

ចំរើនៈ អាយុ៤៧ ។

ប៊ុនថនៈ ពូមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ចំរើនៈ ស្រុកកំណើតនៅភូមិដូនទ្រី ឃុំជ្រៃ ស្រុកមោង ខេត្តបាត់ដំបង ។

ប៊ុនថនៈ បាទ! នៅម៉ោងនោះ?

ចំរើនៈ បាទ ។

ប៊ុនថនៈ តែយកគ្រួសារមីងនៅនេះ?

ចំរើនៈ បាទ ។

ប៊ុនថនៈ ចឹងជួបមីងនៅភូមិនេះតែម្តង?

ចំរើនៈ បាទ ។

ប៊ុនថនៈ ចឹងការរៀបការឆ្នាំណា?

ចំរើនៈ កាលបានគ្នានៅឆ្នាំ៨៦ នៅឆ្នាំ១៩៨៦ ។

ប៊ុនថនៈ បាទ! នៅពេលពូមកនេះ?

ចំរើនៈ បាទ ។

ប៉ុនថន៖	ចឹងពូរៀនដល់កំរិតណាដែលលោកពូ?

ចំរើន៖	ខ្ញុំរៀនបានថ្នាក់ទី១០ពីដើមសង្គមលន់ នល់ ។

ប៉ុនថន៖	រាប់ពីធំមកតូចវិញ?

ចំរើន៖	បាទ!កាលហ្នឹងថ្នាក់ទី១២-១១-១០ចឹងទៅ ។

ប៉ុនថន៖	បាទ!បានបីឆ្នាំទីពា?

ចំរើន៖	បាទ!ទីពាឥឡូវ ។

ប៉ុនថន៖	កាលរៀននៅមោងពូ?

ចំរើន៖	កាលរៀននៅមោងហ្នឹងឯង ។

ប៉ុនថន៖	ចឹងនៅពេលពូឈប់រៀនពូធ្វើអីទៀតលោកពូ?

ចំរើន៖	ឈប់រៀនឪពុកម្ដាយខ្ញុំអត់បានធ្វើអីទេ ដល់ឈប់រៀនដល់ឆ្នាំ៧៥ ។

ប៉ុនថន៖	បាទ ។

ចំរើន៖	៧៥ យើងមិនរំដោះខ្មែរក្រហម ។

ប៉ុនថន៖	បាទ ។

ចំរើន៖	រំដោះហើយយើងមិនចូលសម័យប៉ុល ពតហ្នឹង ។

ប៉ុនថន៖	បាទ ។

ចំរើន៖	ដល់របូតមកពី៧៥ដល់៧៩ខ្ញុំបានភាសខ្លួនមកព្រំដែន ។

ប៉ុនថន៖	ចឹងកាល៧៥ចូលភ្នានហ្នឹងអ្នកភូមិជម្លៀសចេញទេពូ?

ចំរើន៖	បាទ!ជម្លៀសចេញយើងនៅត្រង់នេះត្រង់នោះចឹងទៅ បើយើងមិនបានជម្លៀសទេគេឲ្យនៅហ្នឹងទៅ ។

ប៉ុនថន៖	បាទ ។

ចំរើន៖	ដូចថាភូមិហ្នឹងគេឲ្យនៅហ្នឹងទៅខ្វះក៏ជម្លៀសចេញតាមដំណើរចឹងទៅ ។

ប៉ុនថន៖	បាទ ។

ចំរើន៖	ទៅនៅភូមិនេះភូមិនោះចឹងទៅ ។

ប៉ុនថន៖	បាទ ។

ចំរើន៖	កាលឆ្នាំ៧៥ នោះណាស់ ។

ប៉ុនថន៖	បាទ!កាលជម្លៀសដំបូងទៅខាងណាវិញពូ?

ចំរើនៈ	កាលខ្ញុំជម្លៀសមានបានទៅណាចេញពីដូនទ្រីមក មកនៅម៉ាណោកនៅភូមិអែបៗគ្នាហ្នឹងឯង កាលហ្នឹង ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	ក្នុងឃុំតែមួយទេ ។

ប៊ុនថនៈ	ចឹងក្នុងឃុំតាមួយទេ?

ចំរើនៈ	បាទ! នៅស្រុកមោងហ្នឹងដដែល ។

ប៊ុនថនៈ	ភូមិដូចទ្រីឃុំអីវិញ?

ចំរើនៈ	ភូមិដូនទ្រី ឃុំជ្រៃ ស្រុកមោង បើម៉ាណោកឃុំទម្លាប់មិនដឹង ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	វាមានពីរឃុំកាលហ្នឹង ។

ប៊ុនថនៈ	ចឹងទៅភូមិហ្នឹងគេចាត់តាំងយ៉ាងម៉េចដែលពូ?

ចំរើនៈ	ខ្ញុំនៅភូមិកាលនោះខ្ញុំនៅកុមារ ។

ប៊ុនថនៈ	ចឹងនៅជាកុមារ?

ចំរើនៈ	បាទ! កាលហ្នឹងអាយុនៅតិចដែរ ។

ប៊ុនថនៈ	កាលនោះប្រហែលជាប៉ុន្មាន?

ចំរើនៈ	កាលនោះប្រហែលជា១២ទៅ១៣ឆ្នាំអីកាលហ្នឹង កាលហ្នឹងយុវជនទាល់១៧បានចូលជាយុវជនកាលហ្នឹង ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	យើងត្រឹម១៣ទៅ១៨នៅជាកុមារនៅឡើយទេ ។

ប៊ុនថនៈ	បាទ! នៅជាកុមារ?

ចំរើនៈ	បាទ ។

ប៊ុនថនៈ	ចឹងបងៗលោកពូ?

ចំរើនៈ	ខ្ញុំបងគេ ។

ប៊ុនថនៈ	បងគេចុះប្អូនវិញមានប៉ុន្មាននាក់?

ចំរើនៈ	ប្អូនមាន៣នាក់ ។

ប៊ុនថនៈ	ចឹងនៅជាមួយឪពុកម្ដាយនៅឡើយទេ?

ចំរើនៈ	ម្ដាយនៅបែកពីឪពុកតាំងពីឆ្នាំពីឆ្នាំ៧៥ហ្នឹងមក៧៦-៧៧ហ្នឹងមកបែក ។

ប៊ុនថន: គាត់ទៅណាវិញ?

ចំរើន: បាត់មិនដឹងជាទៅណាកាលសម័យនោះ ។

ប៊ុនថន: ចឹងកាលហ្នឹងគាត់ធ្វើអី?

ចំរើន: កាលនោះខ្ញុំមិនសូវដឹងដែរ ម្តាយខ្ញុំគាត់មិនបានប្រាប់មិនដឹងជាគាត់ធ្វើអី ។

ប៊ុនថន: កាលហ្នឹងពូនៅក្មេង?

ចំរើន: បាទ!នៅក្មេង ។

ប៊ុនថន: ពូអត់ចាំទេចឹង?

ចំរើន: បាទ!មិនចាំទេ មិនជាគាត់ធ្វើអីរកស៊ីអីខ្ញុំមិនដឹងដែរ ។

ប៊ុនថន: ចឹងនៅភូមិហ្នឹងយូរទេ?

ចំរើន: ខ្ញុំនៅភូមិហ្នឹងយូរហ្នឹងឯងខ្ញុំរត់ចេញមកកាលឆ្នាំ៧៩ ។

ប៊ុនថន: ចេញពីភូមិមក?

ចំរើន: ចេញពីភូមិដូនទ្រី ។

ប៊ុនថន: ដូនទ្រី?

ចំរើន: បាទ!ចេញពីភូមិតាំងពី៧៩បានមកនៅនេះរបូត ។

ប៊ុនថន: និយាយនៅហ្នឹងការងាររបបរហូបចុកអីយ៉ាងម៉េចដែរ ភូមិដូនទ្រីហ្នឹង?

ចំរើន: ថាមើលខ្ញុំដូចជានេះដែលកាលឆ្នាំ៧៩មិនវៀតណាមរំដោះ ។

ប៊ុនថន: ចង់និយាយថា៧៥ណាស់?

ចំរើន: ៧៥ យើងនិយាយទៅចូលសម័យគេរំដោះឆ្នាំ៧៥ហ្នឹង ។

ប៊ុនថន: បាទ ។

ចំរើន: ខ្ញុំនៅជាកុមារខ្ញុំមិនទាន់ដឹងអីដែរ យកទៅដាក់មណ្ឌលកុមារទៅហូបចុកដូចដឹងស្រាប់ហើយ បបរមួយវែក ។

ប៊ុនថន: បាទ ។

ចំរើន: បបរមួយវែងក្នុងមួយនាក់ ហើយគេឲ្យធ្វើការទៅ ។

ប៊ុនថន: ការងារមានអីខ្លះពូ?

ចំរើន: ការងារយើងកុមារយើងរើសអាចម៍គោ បោចស្មៅអត់មានធ្វើអីច្រើនទេយើងកុមារមាន បោចស្មៅរើសអាចម៍គោធ្វើជីអីចឹង ។

ប៊ុនថន: បាទ ។

ចំរើនៈ	មិនបានទៅដកស្ទូងអីហ្នឹងគេទេ ។

ប៊ុនថនៈ	ចឹងប្អូនៗលោកពូ?

ចំរើនៈ	ប្អូនៗខ្ញុំនៅជាកុមារជាមួយគ្នាដែរ ។

ប៊ុនថនៈ	នៅកុមារដែរ?

ចំរើនៈ	នៅមណ្ឌលជាមួយគ្នា អត់មានបាននៅជាមួយឪពុកម្ដាយទេ ។

ប៊ុនថនៈ	ចឹងម្ដាយពូ?

ចំរើនៈ	ម្ដាយនៅផ្សេងគាត់ធ្វើការងារផ្សេងនៅសហករណ៍នេះផ្សេង ខ្ញុំកុមារនេះគេឲ្យមកនៅមណ្ឌលកុមារនេះផ្សេងបែកគ្នា ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	មិនបាននៅជាមួយគ្នាទេ ។

ប៊ុនថនៈ	ចឹងពូនៅហ្នឹងរហូតពូ?

ចំរើនៈ	បាទ!ខ្ញុំនៅហ្នឹងរហូត ។

ប៊ុនថនៈ	រហូតដល់វៀតណាមចូលមកហ្នឹង?

ចំរើនៈ	បាទ!រហូតវៀតណាមចូលមកឆ្នាំ៧៩នេះបានខ្ញុំបែកចេញ ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	បែកចេញបានខ្ញុំមកនៅព្រំដែន ។

ប៊ុនថនៈ	នៅខាងណាវិញពូ?

ចំរើនៈ	ខ្ញុំនៅខាងភ្នំឆត្រ ។

ប៊ុនថនៈ	ភ្នំឆត្រ?

ចំរើនៈ	បាទ ។

ប៊ុនថនៈ	ចឹងម្ដាយលោកពូ?

ចំរើនៈ	ម្ដាយខ្ញុំនៅដូនទ្រីប្អូនទាំងអស់នៅដូនទ្រីទាំងអស់ ។

ប៊ុនថនៈ	ចឹងពូមកនេះតែមួយទេ?

ចំរើនៈ	បែកតែខ្ញុំម្នាក់ ។

ប៊ុនថនៈ	ម៉េចបានបែកមកតែម្នាក់ឯងចឹងពូ?

ចំរើនៈ	កាលហ្នឹងវៀតណាមរំដោះមកចឹងទៅគាត់នៅទៅខ្ញុំក៏មិនបាននៅ កាលហ្នឹងគេថាមករត់ពន្ធផ្លូវខាងលិចនេះ ខ្ញុំចេះតែដើរតាមគេមក ។

ប៊ុនថន: ចឹងមានអ្នកបបួលមក?

ចំរើន: បាទ!មានអ្នកបបួលមក មកនៅចំការគក្នុំឆ្ន័ត្រយើងនេះ ។

ប៊ុនថន: បាទ!ថាមកជាមួយពួហ្នឹង?

ចំរើន: បាទ!ដល់មកជាប់នៅព្រំដែនរបូតហ្នឹងបណ្តោយ ។

ប៊ុនថន: មានអ្នកមកច្រើនទេ មកពីខាងហ្នឹង?

ចំរើន: អត់ទេ មកតែពីរនាក់ ប៉ុនៗគ្នាចេះតែដើរមក ដើរពីមោងមករបូតមក ។

ប៊ុនថន: បាទ ។

ចំរើន: កាលហ្នឹងមានអីជិះអត់ ។

ប៊ុនថន: បាទ!ហើយកងទ័ពអីគេមានមកច្រើនទេ?

ចំរើន: កងទ័ពវៀតណាមអី ។

ប៊ុនថន: ខ្មែរក្រហម?

ចំរើន: ខ្មែរក្រហមអត់មានទេ រត់អស់ហើយហ្នឹងនៅតែកងទ័ពវៀតណាមកាលនោះហ្នឹង ។

ប៊ុនថន: បាទ ។

ចំរើន: យើងចេះតែដើរៗមក ។

ប៊ុនថន: ចុះពួមកអីដែរ?

ចំរើន: អត់អីទេ ។

ប៊ុនថន: ចឹងនៅខាងក្នុំឆ្ន័ត្រនេះពួមកដល់ហ្នឹងមានឃើញមនុស្សច្រើនទេកាលហ្នឹង?

ចំរើន: នៅក្នុំឆ្ន័ត្រហ្នឹងមិនសូវមានច្រើនទេ មានតិចតួចទេកាលកងទ័ពខ្មែរក្រហម ។

ប៊ុនថន: បាទ ។

ចំរើន: មិនទាន់មានជំរំឡូវាណែទឡូហ៊ីកហាកអីវាអត់ទេ ។

ប៊ុនថន: បាទ ។

ចំរើន: វាមានតិចតួចមានអ្នកទៅដូចខ្ញុំចេះ ចេះតែនៅតិចតួចៗចឹងទៅដល់ឆ្នាំ៨០-៨១នោះបាន ច្រើនកាលហ្នឹង ។

ប៊ុនថន: បាទ ។

ចំរើន: បានមានប្រជាជនរត់ពន្ធហើយកាលឆ្នាំ៨០ហ្នឹង គគ្រឹកគគ្រែង ។

ប៊ុនថន: រត់ពន្ធហ្នឹងរត់អីវិញលោកពូ?

ចំរើន: រត់ពន្ធហ្នឹងដូចថាគេទិញទំនិញពីថៃមកលក់អីស្វាយយើងនេះ ។

ប៊ុនថន: បាទ ។

ចំរើន: មានក្រណាត់សារ៉ុង បារីយើងយកមកលក់នៅនេះមានកង់មានអីចឹងទៅ ។

ប៊ុនថន: បាទ ។

ចំរើន: អ្នករកស៊ីចេះតែទិញយកមកលក់នៅថៃ ខ្ញុំក៏នៅជាមួយគេចឹងទៅ ។

ប៊ុនថន: នៅខាងជាមួយខ្មែរក្រហមហ្នឹងពូ?

ចំរើន: បាទ ។

ប៊ុនថន: ពូចូលខាងកងទ័ពវិញ?

ចំរើន: បាទ!ខ្ញុំអត់មានបានរកអីចូលខាងកងទ័ពរហូត ។

ប៊ុនថន: ម៉េចបានជាពូទៅខាងកងទ័ពវិញ?

ចំរើន: ដូចថាយើងអត់មានគោលដៅអ៊ីមួយយើងត្រូវចូលជាមួយគេសិនទៅ ។

ប៊ុនថន: បាទ ។

ចំរើន: ចុះកាលហ្នឹងយើងនៅក្មេងយើងចេះតែធ្វើហ្នឹងគេទៅ ។

ប៊ុនថន: ចឹងពូរបស់ពូដែលថាទៅជាមួយគ្នានោះ?

ចំរើន: បែកបាក់គ្នាមិនដឹងជាទៅណាទៅណីអស់ទៅ មិនដឹងជាទៅរកស៊ីអីនៅតែខ្ញុំមួយទៅ ។

ប៊ុនថន: ចឹងពូនៅជាមួយខ្មែរក្រហមហ្នឹងនៅវរៈកងពលលេខប៉ុន្មាន?

ចំរើន: នៅកងពល៥១៩ ។

ប៊ុនថន: ចឹងប្រធាន?

ចំរើន: បងសារឿន ។

ប៊ុនថន: ពូសារឿន?

ចំរើន: បាទ ។

ប៊ុនថន: គាត់នៅរស់ដែលរាល់ថ្ងៃហ្នឹង?

ចំរើន: គាត់នៅស្វាយរាល់ថ្ងៃហ្នឹង តែគាត់មានធ្វើអីទេសព្វថ្ងៃគាត់ឈប់ធ្វើអីអស់ហើយ ។

ប៊ុនថន: ចឹងប្រជាជនរត់ពន្ធចេញចូលអត់មានអីដែរ ខ្មែរក្រហមបើកឲ្យចូល?

ចំរើន: អត់អីទេ កាលហ្នឹងមានជំរំខ្មែរក្រហមមានជំរំប៉ារាអីហ្នឹង ជំរំថ្មីជំរំប៉ារា ចំការគខ្មែរក្រហម ចឹងទៅ ។

ប៊ុនថន: ចឹងនៅជិតៗគ្នាពូ?

ចំរើន: បាទ!ជិតៗគ្នាជាប់គ្នាហ្នឹងអ្នកប្រជាជនចេញតែចេញចូលរកស៊ីទៅ ។

ប៊ុនថន:	ចឹងកាលពូទៅមានហាត់អីទេកាលទៅហ្នឹង?

ចំរើន:	អត់មានហាត់អីផង អត់មានពីណាបង្ហាត់អីផង ។

ប៊ុនថន:	មានឡើងវ៉ៃអីទេ កាលហ្នឹង?

ចំរើន:	កាលនោះមិនទាន់ឡើងវ៉ៃទេ នៅក្នុងជំរំអត់មានវ៉ៃអីទេកាលហ្នឹង ។

ប៊ុនថន:	តែក្រោយមកមានបានឡើងវ៉ៃទេកាលហ្នឹង?

ចំរើន:	ក្រោយមកឆ្នាំ៨៣ កាល៨៣បានកងទ័ពវៀតណាមនិងទាហានយើងនេះទៅវ៉ៃជំរំបែក ។

ប៊ុនថន:	ទាហានណា?

ចំរើន:	ទាហានកងទ័ពវៀតណាមនិងទាហានខ្មែរយើងហ្នឹង ។

ប៊ុនថន:	ទាហានរដ្ឋកម្ពុជា?

ចំរើន:	បាទ!ទាហានរដ្ឋកម្ពុជាហ្នឹងទៅវ៉ៃជំរំបែក ជំរំចំការគបានបែកជំរំភ្នំឆត្រ ។

ប៊ុនថន:	ជំរំភ្នំឆត្រហ្នឹងនៅក្នុងស្រុកអីវិញលោកពូភូមិឃុំអីវិញ?

ចំរើន:	ជំរំភ្នំឆត្រហ្នឹងមិនដឹងជាស្រុកអីឃុំអីទេនេះ នៅបន្ទាយមានជ័យនេះឯង ។

ប៊ុនថន:	តែស្រុកអីវិញ?

ចំរើន:	ដូចជានៅស្រុកស្វាយចេក ។

ប៊ុនថន:	ស្វាយចេកដែរ?

ចំរើន:	បាទ!ស្រុកស្វាយចេកព្រោះអីនៅខាងលិចស្វាយចេកនេះឯង ។

ប៊ុនថន:	បាទ ។

ចំរើន:	ស្រុកស្វាយចេកហើយ ភ្នំឆត្រចំការគហ្នឹងស្រុកស្វាយចេកហើយខេត្តយើងនេះឯង ។

ប៊ុនថន:	ចឹងកងទ័ពវៀតណាមវ៉ៃចូលដល់ហ្នឹងលោកពូ?

ចំរើន:	បាទ!វ៉ៃចូលដល់កាលឆ្នាំ៨៣ ។

ប៊ុនថន:	ដល់ចឹងពូរត់នៅណាទៀត?

ចំរើន:	ខ្ញុំរត់ទៅដីថៃ ។

ប៊ុនថន:	រត់ចូលថៃ?

ចំរើន:	បាទ!រត់ចូលដីថៃបានប្រជាជននៅជំរំហ្នឹងចូលទៅជំរំទាំងអស់ បានគេដឹកប្រជាជនទៅជំរំហ្នឹងទៅនៅជំរំម៉ាឡៃនោះ ។

ប៊ុនថន:	ជំរំ៨៥អីហ្នឹង?

ចំរើន:	បាទ!៨៥ គេដឹកទៅនោះឯង ។

ប៊ុនថន៖	ចឹងពូមានបានទៅដល់ហ្នឹងដែរ?

ចំរើន៖	ខ្ញុំទៅដល់ដំរី៨៥ហ្នឹងបានខ្ញុំបកមកវិញ ។

ប៊ុនថន៖	បកមកវិញ?

ចំរើន៖	បកមកកន្លែងកងទ័ពនេះវិញ ។

ប៊ុនថន៖	កន្លែងភ្នំឆត្រនេះវិញ?

ចំរើន៖	បាទ ។

ប៊ុនថន៖	ចឹងវៀតណាមវ៉ៃហើយវៀតណាមដកចេញវិញ?

ចំរើន៖	ដកចេញវិញហើយបានគេរៀបកំលាំងនៅភ្នំឆត្រនេះវិញ ។

ប៊ុនថន៖	នៅដដែលវិញ?

ចំរើន៖	បាទ!ដល់ហើយ នៅភ្នំឆត្រដដែលកាលហ្នឹង ។

ប៊ុនថន៖	ចឹងក្រោយមកមានប៉ះគ្នាទៀតទេពូ?

ចំរើន៖	ក្រោយមកបានគេបំបែកកងទ័ពមកចុះមកស្រុកខ្មែរវិញ ចុះមកនៅតាមភូមិឃុំយើងនេះ ។

ប៊ុនថន៖	បាទ ។

ចំរើន៖	រាយកំលាំងតាមហ្នឹង ។

ប៊ុនថន៖	រាយទៅណាខ្លះរាយទៅស្រុកណាខ្លះពូ?

ចំរើន៖	ខ្ញុំដឹបូងគេឲ្យចុះទៅខាងទន្លេសាបនោះ ទៅខាងបបោសកំពង់ក្រសាំងក្រោមនោះ ។

ប៊ុនថន៖	ហ្នឹងនៅក្នុងស្រុអីវិញ?

ចំរើន៖	បបោសកំពង់ក្រសាំងស្រុកមង្គលបូរីមិនដឹងជាស្រុកអីទេ ។

ប៊ុនថន៖	បាទ ។

ចំរើន៖	នៅខាងកើតមង្គលបូរីនេះ ។

ប៊ុនថន៖	បាទ ។

ចំរើន៖	តែមិនដឹងស្រុកអីកាលហ្នឹងខាងកើតមង្គលបូរីហ្នឹងមិនសូវដឹងដែរ ។

ប៊ុនថន៖	បំបែកចេញជាច្រើនក្រុមទេបំបែងចេញ?

ចំរើន៖	មួយកងពលនោះបំបែក ។

ប៊ុនថន៖	កងពលមានគ្នាប៉ុន្មាននាក់លោកពូប៉ុន្មានពាន់នាក់?

ចំរើន៖	ទេ មួយកងពលមានច្រើនដែរ បំបែកមកប្រហែលជាមួយពាន់ជាង ។

ប៊ុនថន៖	ចឹងបំបែកមកមួយក្រុមទៅនៅចឹងមានគ្នាប៉ុន្មាននាក់ពូ?

ចំរើនៈ	មួយក្រុមតាមកងវរៈៗមួយវរៈសេនាតូចៗមួយវរៈសេនាធំ ។

ប៊ុនថនៈ	ទៅនៅតាមភូមិ?

ចំរើនៈ	ទៅតាមភូមិតាមព្រៃចឹងទៅចេះតែនៅទៅ ។

ប៊ុនថនៈ	ចឹងដូចជាការផ្គត់ផ្គង់អីធ្វើយ៉ាងម៉េចទៅពូ ស្បៀង?

ចំរើនៈ	ការផ្គត់ផ្គង់កាលនោះ ស្បៀងអីគេដោះស្រាយបានដូចជាសម្ភារផង់ាំងអីហ្នឹងគេចេះដោះស្រាយមកឲ្យតើ ។

ប៊ុនថនៈ	បញ្ជូនមកពីណា?

ចំរើនៈ	បញ្ជូនមកតាមព្រំដែនហ្នឹងហើយ ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	គេដឹកជញ្ជូនយកទៅឲ្យ ។

ប៊ុនថនៈ	ចឹងកាលហ្នឹងពូនៅវរៈប៉ុន្មានពូ?

ចំរើនៈ	ខ្ញុំនៅវរៈ៣៨០ ។

ប៊ុនថនៈ	៣៨០?

ចំរើនៈ	បាទ ។

ប៊ុនថនៈ	កាលហ្នឹងនៅជាមួយពីណាវិញកាលបំបែកហ្នឹង?

ចំរើនៈ	គាត់ស្លាប់បាត់ហើយ ខ្មោចលីនគាត់ស្លាប់ ។

ប៊ុនថនៈ	ឈ្មោះអីវិញ?

ចំរើនៈ	ឈ្មោះ លីនគាត់ស្លាប់ហើយ ។

ប៊ុនថនៈ	តែគាត់តស៊ូពីដើមដែលលីនហ្នឹង?

ចំរើនៈ	បាទ!គាត់តស៊ូពីដើមដែរ អ្នកដែលកាលហ្នឹងស្លាប់អស់ហើយដូចជាខ្មោចបងឈនអីស្លាប់អស់ដែរ ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	សុទ្ធតែអ្នកគេតស៊ូពីដើមហើយហ្នឹងនោះ ។

ប៊ុនថនៈ	បាទ ។

ចំរើនៈ	គេសុទ្ធតែចាស់ៗហើយ ។

ប៊ុនថនៈ	ពូនៅយូរទេ ពូចុះទៅនៅបឹងទន្លេសាបហ្នឹង?

ចំរើនៈ កាលហ្នឹងទៅនោះបានតែមួយឆ្នាំ បានចុងក្រោយមក៨៤-៨៥ខ្ញុំនៅនេះតែម្ដងខ្ញុំនៅឈរជើងនៅផ្គាំហ្នឹងតែម្ដង ។

ប៊ុនថនៈ នៅផ្គាំហ្នឹង?

ចំរើនៈ បាទ!៨៥-៨៦ហ្នឹងខ្ញុំនៅនេះរហូត ។

ប៊ុនថនៈ ទីតាំងគេធំនៅណាវិញ?

ចំរើនៈ ទីតាំងធំនៅតាមព្រំដែនហ្នឹងឯង ។

ប៊ុនថនៈ តែថាវាយមកប្រចាំការចឹង?

ចំរើនៈ អត់មានកំណត់គ្នាទីតាំងធំទេ ចល័តរហូត ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ត្រូវទៅនៅភូមិនេះបន្តិចភូមិនោះបន្តិចដូចជាអំពិលអំពែកចឹងរកគោលដៅអត់ឃើញ ។

ប៊ុនថនៈ ចឹងនៅផ្គាំនេះ៨៤ហើយពូ?

ចំរើនៈ បាទ!៨៤-៨៥-៨៦នៅរហូត ។

ប៊ុនថនៈ ចឹង៨៥-៨៦ហ្នឹងពូចូលមកមានប្រជាជននៅហ្នឹងទេ?

ចំរើនៈ ប្រជាជននៅពេលនេះទាំងអស់ហ្នឹង ។

ប៊ុនថនៈ ចឹងមកនៅលាយជាមួយប្រជាជន?

ចំរើនៈ បាទ!មកនៅជាមួយប្រជាជននេះឯង ។

ប៊ុនថនៈ ចឹងមានវៀតណាមអីចូលមកទេ?

ចំរើនៈ មានកងទ័ពវៀតណាមនិងទាហានខាងខ្មែរយើងមកវ៉ៃគ្នាចុះឡើងៗហ្នឹងទៅមកៗហ្នឹងឯង ។

ប៊ុនថនៈ បាទ ។

ចំរើនៈ គេមកយើងចេញទៅដល់គេទៅវិញយើងចូលមក ។

ប៊ុនថនៈ ប៉ុន្តែមានវ៉ៃគ្នាទេ?

ចំរើនៈ មាន រឿងអស់នេះមានប៉ះគ្នាវ៉ៃគ្នា ។

ប៊ុនថនៈ វ៉ៃគ្នាមិនមែនគ្នានៅក្នុងភូមិទេទៅវាល?

ចំរើនៈ បាញ់ក្នុងភូមិបាញ់អីដែលហ្នឹង ។

ប៊ុនថនៈ ចឹងនៅពេលពូមកហ្នឹងប្រជាជនយ៉ាងម៉េចដែរ និយាយថាប្រជាជនស្វាគមន៍ឬមួយយ៉ាងម៉េចដែរ?

ចំរើនៈ ប្រជាជននិយាយទៅគាត់អត់មានប្រកាន់ខាងណាខាងណី ខ្ញុំមកសុំបាយហូបគាត់ឲ្យបាយហូបទៅ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ខាងនោះមកសុំបាយហូបគាត់ឲ្យបាយហូបទៅ ព្រោះគាត់ត្រូវមានអំរែក ។

ប៊ុនថនៈ បាទ!អត់មានប្រកាន់ខាងណាបាន?

ចំរើនៈ អត់មានទេ អត់មានប្រកាន់ខាងណាបានទេ គាត់ជាអាជ្ញាកណ្តាលគាត់មានអំរែក ។

ប៊ុនថនៈ បាទ ។

ចំរើនៈ គាត់មិនហ៊ានពន្ធទេ ។

ប៊ុនថនៈ ចឹងមានប្រជាជនខ្លះមានរាយការណ៍ឲ្យខាងនោះ មានរាយការណ៍ឲ្យខាងនេះមានទេ?

ចំរើនៈ កាលហ្នឹងវាអាចមានខ្លះដែរ តែយើងជាអ្នកចេះមិនដឹងជាពីណារាយទៅខាងណាយើងអត់ដឹង ។

ប៊ុនថនៈ បាទ!អត់ដឹងទេ?

ចំរើនៈ បាទ ។

ប៊ុនថនៈ ចឹងពេលមកហ្នឹងសំខាន់យកទីតាំងឬមួយក៏យ៉ាងម៉េច?

ចំរើនៈ សំខាន់មិនដឹងជាគោលការណ៍នយោបាយគេយ៉ាងម៉េចគេឲ្យមកយើងចេះតែមកទៅ ។

ប៊ុនថនៈ ចឹងពូអត់ដឹងដែរ?

ចំរើនៈ អត់ដឹងដែរ គេថាឲ្យនៅមុខសញ្ញាផ្កាំចេះយើងចេះតែនៅទៅ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ យើងមិនបានដឹងថាគោលការណ៍គេយ៉ាងម៉េចយើងមិនដឹង ។

ប៊ុនថនៈ ចឹងខាងប៉ុលពតនោះមានមកទេ?

ចំរើនៈ ខាងប៉ុលពតក៏មានមក ខាងប៉ុលពតក៏មកនៅឈរជើងនេះទាំងអស់ ។

ប៊ុនថនៈ ចឹងខាងប៉ុលពតឈរជាមួយខ្មែរក្រហមឬមួយយ៉ាងម៉េចដែរ?

ចំរើនៈ បាទ!នៅជាមួយគ្នាគ្រាន់តែរង្វង់ថាគេកងគេផ្សេងទៅ ខាងខ្មែរក្រហមហ្នឹងកងគេផ្សេងទៅ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ហូបចុកដេកពួនអីគេដេកខាងគេទៅយើងដេកខាងយើងនេះទៅ តែដើរចូលភូមិចូលមកទាំងអស់គ្នា ។

ប៊ុនថនៈ ចឹងចូលមកទាំងអស់គ្នា?

ចំរើនៈ បាទ ។

ប៊ុនថនៈ ចឹងអត់មានប៉ះគ្នាទេពូ?

ចំរើនៈ អត់មានទេ អត់មានទំនាស់គ្នាអីទេ ។

ប៊ុនថនៈ ចឹងប៉ះតែជាមួយវៀតណាមទេ?

ចំរើនៈ បាទ!រឿងខ្មែរក្រហមអត់មានទំនាស់គ្នាទេ បើមានទំនាស់គ្នាទំនាស់រវាងបុគ្គលទេដែលខឹងគ្នានោះណា ។

ប៊ុនថនៈ បាទ!ខឹងយ៉ាងម៉េចវិញពូ?

ចំរើនៈ ខឹងគ្នាទាស់សម្តីគ្នាឧទាហរណ៍ថា យើងប្រអាប់គេប្រអាប់យើងអីចឹងខឹងគ្នាទៅ ។

ប៊ុនថនៈ ចឹងមានបាញ់គ្នាមានអីទេ?

ចំរើនៈ មានដែលហ្នឹង ។

ប៊ុនថនៈ ឈ្មោះគ្នាហ្នឹងតែមេៗទេឬមួយកូនចៅ?

ចំរើនៈ កូនចៅហ្នឹងមេៗមិនអីតែកូនហ្នឹង ។

ប៊ុនថនៈ ខាងប៉ារាខាងណាអ្នកនាំចូលមក?

ចំរើនៈ ខាងប៉ារាចំរុះខាងសាយធូខាងសាយប៊ីមានពីរជំរំ ។

ប៊ុនថនៈ ចឹងមានពីរជំរំ?

ចំរើនៈ បាទ ។

ប៊ុនថនៈ សាយធូពីណាជាអ្នកគ្រប់គ្រង?

ចំរើនៈ សាយធូកាលនោះដូចជាលោកតា សឺន សាន ។

ប៊ុនថនៈ បាទ ។

ចំរើនៈ សាយធូខ្ញុំមិនសូវដឹងដែលទេ ខ្ញុំដឹងថាលោកតា សឺន សាន ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ហើយទៅខាងសាយប៊ីនោះខាងសម្តេចក្រុមព្រះចឹងឯងកាលហ្នឹង ។

ប៊ុនថនៈ ចឹងខាងប៉ារាមានកំលាំងពីរចំរុះមក?

ចំរើនៈ បាទ!កំលាំងពីរចំរុះ ។

ប៊ុនថនៈ ចឹងដូចថាមានវៃជាមួយវៀតណាមអីចឹងកំលាំងពីរហ្នឹងវៃតែម្តងឬក៏?

ចំរើនៈ កំលាំងខាងវៀតណាមនិយាយទៅថា ប៉ះប៉ារាវៃជាមួយប៉ារាប៉ះខាងខ្មែរក្រហមវៃជាមួយខ្មែរក្រហម ។

ប៊ុនថន: ចង់និយាយថាខ្មែរក្រហមផ្ទុកកំលាំងជាមួយប៉ារាវៃវិញបុកប៉ះតែមួយៗទេ?

ចំរើន: ដូនកាលហ្នឹងមេៗហ្នឹងចង់វៃទីតាំងណាមួយគេអាចផ្ទុកគ្នាដែរ ។

ប៊ុនថន: បាទ ។

ចំរើន: មានប៉ារាមានខ្មែរក្រហមគេពិភាក្សាគ្នាអាចផ្ទុកវៃដែរទីតាំងមួយៗចឹងទៅ ។

ប៊ុនថន: ពូឈរជើងនៅនេះបានយូរទេពូ?

ចំរើន: ខ្ញុំតាំងពី៨៥មកនៅនេះរហូតដល់និយាយរួមដល់ត្រូវរូវគ្នានៅឆ្នាំ៩៣ ។

ប៊ុនថន: នៅពេលបោះឆ្នោតហ្នឹង?

ចំរើន: បាទ ។

ប៊ុនថន: ចឹងកំលាំងខ្មែរក្រហមនៅហ្នឹងរហូតចឹង?

ចំរើន: កំលាំងខ្មែរក្រហមនៅតាមជំរំដងរែកភ្នំឆត្រ កំលាំងធំគេ ។

ប៊ុនថន: បាទ!ចឹងកំលាំងដាក់មកតាមភូមិចឹងមានដកទៅវិញទេ?

ចំរើន: អត់ទេ អត់ដកទេត្រូវរូវគ្នាហើយ ត្រូវរូវគ្នាជាមួយខាងនេះអស់ហើយកាលហ្នឹង៩៣អាចបោះឆ្នោតត្រូវរូវគ្នាហើយកាលហ្នឹង ។

ប៊ុនថន: បាទ ។

ចំរើន: មានអី ។

ប៊ុនថន: ចឹងកាលហ្នឹងខ្មែរក្រហមមិនទាន់ចុះចូលទេពូកាលហ្នឹង ចូលតែខាងប៉ារាទេ?

ចំរើន: កាលហ្នឹងប៉ារាក៏ចុះចូលខ្មែរក្រហមក៏ចុះចូលតែដល់ពេលបោះឆ្នោតឆ្នាំ៩៣នេះ វាមានផ្ទុះសាយមួយ ។

ប៊ុនថន: ផ្ទុះសារាយយ៉ាងម៉េចទៅ?

ចំរើន: ខ្មែរក្រហមវៃប៉ារាបណ្តេញចេញវិញ បានមានអូសបន្លាយសង្គ្រាមហ្នឹងបានរយៈពីរឆ្នាំខ្ញុំដូចជាភ្លេចដែរ ។

ប៊ុនថន: បាទ ។

ចំរើន: ខ្មែរក្រហមវាចេញទៅនៅតាមព្រំដែនវិញ ។

ប៊ុនថន: ហេតុអីបានជាវៃជាមួយប៉ារាពូ?

ចំរើន: ប៉ារាគេវៃមក ។

ប៊ុនថន: ចឹងប៉ារាវៃខ្មែរក្រហម?

ចំរើន: បាទ!វៃបណ្តេញចេញវិញ ។

ប៊ុនថន៖ ចឹងពូមានចេញទេ?

ចំរើន៖ ខ្ញុំអត់ខ្ញុំឈប់ហើយ ។

ប៊ុនថន៖ ចឹងឈប់ធ្វើខ្មែរក្រហម?

ចំរើន៖ បាទ!ខ្ញុំឈប់ធ្វើហើយខ្ញុំនៅនេះរហូតតាំងពី៩៣មកខ្ញុំនៅនេះរបូតពីណាធ្វើអីខ្ញុំអត់ដឹងខ្ញុំជាប្រជាជនហើយ ។

ប៊ុនថន៖ បាទ ។

ចំរើន៖ ខ្ញុំរកស៊ីដល់នេះខ្មែរក្រហមទៅនៅតាមព្រំដែនវិញ ខាងទាហានខ្មែរចាប់ដៃគ្នាទៅវ៉ៃខ្មែរក្រហម ។

ប៊ុនថន៖ បាទ ។

ចំរើន៖ វ៉ៃនៅស្វាច់ អន្លង់វែង ម៉ាឡៃ ប៉ៃលិនអីហ្នឹង ។

ប៊ុនថន៖ បាទ ។

ចំរើន៖ ដល់រួចមកសម្តេចសម្រុះសម្រួលគ្នាចូលមកសាភាពអស់ ។

ប៊ុនថន៖ បាទ ។

ចំរើន៖ ចឹងទៅ៩០ប៉ុន្មានទេខ្ញុំភ្លេចហើយ ។

ប៊ុនថន៖ ៩៦-៩៧?

ចំរើន៖ ប្រហែលជាប៉ុណ្ណឹងដឹង ។

ប៊ុនថន៖ ចឹងពូនៅឈរជើងនេះចង់សួរស្ថានភាពភូមិអីចឹង ប្រជាជនមានការរស់នៅយ៉ាងម៉េចដែរពូជីវភាពរបស់គាត់យ៉ាងម៉េចដែលព្រោះដោយសារសង្គ្រាមអីចឹង?

ចំរើន៖ កាលខ្ញុំតាមដានខ្ញុំដើរនៅជីវភាពគាត់តាំងពីខ្ញុំនៅជីវភាពគាត់ពិបាកដែរ ។

ប៊ុនថន៖ បាទ ។

ចំរើន៖ មានខ្វះច្រើនដល់បោះឆ្នោតរួចមក៩៣ហ្នឹងមកជីវភាពគាត់ចេះតែកើនឡើងៗរហូតដល់សព្វថ្ងៃឃើញធូរធារច្រើន ។

ប៊ុនថន៖ បាទ ។

ចំរើន៖ កាលនៅសង្គ្រាមជីវភាពគាត់យ៉ាប់មែនទែន ។

ប៊ុនថន៖ បាទ ។

ចំរើន៖ អានេះខ្ញុំសង្កេតមើលជាក់ស្តែងរបស់ខ្ញុំ ខ្ញុំដើរគ្រប់ភូមិមើលទៅយ៉ាប់ ។

ប៊ុនថន៖ បាទ ។

ចំរើនៈ លំបាកតែម្តងតាំងពី៩៣បោះឆ្នោតហ្នឹងមកជីវភាពធូរធារគ្រប់តែភូមិគ្រប់តែកន្លែងចេះរកស៊ីចេះអីចឹងទៅ ។

ប៊ុនថនៈ ចឹងកាលពូចូលកាលឆ្នាំ៨៤ហ្នឹងមានប្រជាជនច្រើនទេពូ?

ចំរើនៈ កាលខ្ញុំចូលមកឆ្នាំ៨៤ប្រជាជនមួយភូមិៗមានតិចតែទេ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ មួយភូមិៗមានមិនច្រើនទេ ។

ប៊ុនថនៈ ប្រហែលជាប៉ុន្មានគ្រួសារដែរ?

ចំរើនៈ ខ្ញុំកាលហ្នឹងបាន់វាមិនត្រូវ ។

ប៊ុនថនៈ តែមានផ្ទះច្រើនជាប់ៗគ្នាដូចឥឡូវទេ?

ចំរើនៈ បាទ!អត់មានដូចឥឡូវទេ ក្នុងមួយភូមិៗតិចណាស់ ខ្ញុំតាមវិភាគមើលទៅខ្លះគេបំបែកទៅសាយធូខ្លះគេបំបែកទៅសាយប៊ី ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ខ្លះគេបែកទៅជំរំខ្មែរក្រហមភ្នំឆត្រដងរែក ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ដល់ហើយក្នុងភូមិមួយៗវាខោច ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ដល់៩៣នេះបានចាប់ផ្តើមចុះមកសាយធូចុះមកសាយប៊ី ចុះមកពីជំរំដងរែកភ្នំឆត្រអីបានឃើញមានច្រើនទៅៗ ។

ប៊ុនថនៈ បាទ!កាលសង្គ្រាមហ្នឹងដូចថាប្រជាជនមានរបួសមានអីដែលកាលហ្នឹង?

ចំរើនៈ ប្រជាជនមានរបួសដែរ មានរបួសត្រូវគ្រាប់ដែលយើងបាញ់គ្នាហ្នឹងហើយមានរបួសនិងមីន ។

ប៊ុនថនៈ ចឹងមានមីនដែរ?

ចំរើនៈ បាទ!មីន ។

ប៊ុនថនៈ មីនខាងណាជាអ្នកដាក់ទៅពូ?

ចំរើនៈ មីន និយាយទៅវាចំរុះ ខាងប៉ុារាខ្មែរក្រហមទ័ពខាងក្នុងក៏មានដាក់ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ដល់ហើយវាចំរុះមិនដឹងជាមីនខាងណាខាងណីទេ ។

ប៉ុនថន: ចឹងកាលពូមកដល់ដំបូងមានមីនទេ កាលឆ្នាំ៨៣-៨៤ហ្នឹង?

ចំរើន: កាលឆ្នាំ៨៣-៨៤ហ្នឹងមិនទាន់មានប្រើមីនទេ មិនទាន់មានទេ។

ប៉ុនថន: នៅតំបន់នេះមិនទាន់មានទេ?

ចំរើន: បាទ!មិនទាន់មានទេ ចាប់ផ្ដើមមានមីនឆ្នាំ៨៥-៨៦ចាប់ផ្ដើមមានមីនហើយកាល៨៣មាន ដែលតែមិនទាន់ប្រើទេ។

ប៉ុនថន: មានអ្នករបួសច្រើនទេ ដោយសារគ្រាប់មីនហ្នឹង?

ចំរើន: មានច្រើនបើនិយាយនៅក្នុងភូមិឃើញមានកំបុតដៃកំបុតជើងបីបួននាក់ដែលក្នុងភូមិ។

ប៉ុនថន: បាទ។

ចំរើន: ភូមិនេះមានពីរនាក់ដែរ កំបុតជើងដោយសារមីន។

ប៉ុនថន: តែឥឡូវអស់ហើយពូក៏មានខ្វះ?

ចំរើន: ឥឡូវនិយាយមីនមានតែម្ដុំដីឡូតា គល់នេះ តែឥឡូវស៊ីម៉ាកគេដោះអស់ហើយមិនឃើញ មានទេ កាលហ្នឹងមាននៅហ្នឹងឯងមានច្រើនស៊ីម៉ាកគេដោះមួយសារហ្នឹង។

ប៉ុនថន: បាទ។

ចំរើន: ដីងអស់ដីងនៅគេចេញហើយប្រហែលជាអស់ហើយបានបងប្អូននៅអត់មានឃើញអីផង។

ប៉ុនថន: តែកាលមិនមានរាយគ្រប់ភូមិមីន?

ចំរើន: កាលហ្នឹងមានរាយគ្រប់ភូមិមានតែតាមផ្លូវ មិនក្រវ៉ាត់ភូមិរាយទាំងអស់ទេមានរាយតែតាម ផ្លូវ កន្លែងណាសំខាន់ដូចជាដីឡូតា គល់មានគេនៅចឹងបានគេដាក់ច្រើន។

ប៉ុនថន: បាទ!ចឹងសាលារៀនអីមានទេ កាលមកដល់ដំបូង?

ចំរើន: សាលារៀនមាន។

ប៉ុនថន: សាលារៀនវត្តអី?

ចំរើន: មាន។

ប៉ុនថន: មានរួចហើយកាលពូមកដល់៨៤ហ្នឹង?

ចំរើន: បាទ!មានសាលារៀនមានវត្តមានលោកអីទាំងអស់។

ប៉ុនថន: បាទ។

ចំរើន: តែសាលារៀនដូចជាដីងស្រាប់ហើយកាលហ្នឹង សាលារៀនបែកបាក់ខ្ទិចខ្ទីរយើងទើបធ្វើ សង់អីចឹងខ្ញុំមើលឃើញអាហ្នឹងណាស់។

ប៉ុនថន: បាទ។

ចំរើនៈ មានសាលារៀនមានវត្តលោកមានអីធម្មតាហ្នឹង ។

ប៊ុនថនៈ បាទ ។

ចំរើនៈ រហូតទាល់សព្វថ្ងៃហ្នឹងទៅ ។

ប៊ុនថនៈ ចឹងពូការជាមួយអ្នកមីងឆ្នាំណាពូ?

ចំរើនៈ ការឆ្នាំ៨៦ ។

ប៊ុនថនៈ ៨៦?

ចំរើនៈ ខ្ញុំបានឆ្នាំ៨៦ ។

ប៊ុនថនៈ ចឹងគាត់រស់នៅភូមិឃុំហ្នឹងតែម្តង?

ចំរើនៈ បាទ!គាត់រស់នៅភូមិហ្នឹងតែម្តង ។

ប៊ុនថនៈ និយាយថាការហ្នឹងយ៉ាងម៉េច ដូចថារៀបជាគូរៗដូចកាលជំនាន់បីឆ្នាំឬមួយយើងស្រឡាញ់គ្នា?

ចំរើនៈ សម័យឆ្នាំ៨៦ហ្នឹងអត់មានការគូរៗដូចសម័យប៉ុល ពតសម័យបីឆ្នាំអីគេការធម្មតាចឹងឯងតែវាមិនទាន់មានតុមានទីញអីទេ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ គេសែនព្រេនដូចយើងធម្មតាហ្នឹង ។

ប៊ុនថនៈ បាទ ។

ចំរើនៈ គេសែនព្រេនធម្មតាចឹងទៅអត់មានចាប់ផ្ទឹមគូរអីដូចពីដើមអត់ទេ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ មានភ្លេងមានភ្ញាត់ដូចសព្វថ្ងៃចឹងឯង ។

ប៊ុនថនៈ បាទ ។

ចំរើនៈ តែគ្រាន់ថាវាមិនមានកម្មវិធីឡើងតុឡើងអីដូចយើងសព្វថ្ងៃអត់ទេ មិនទាន់មានដល់ប៉ុណ្ណោះទេ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ គ្រាន់មានដាក់ឈើធ្វើក្របចឹងទៅឲ្យមានភ្ញៀវមកអង្គុយលេងហូបចុកនៅតុហ្នឹងប៉ុណ្ណោះឯងតែប៉ុណ្ណឹងទេ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ អត់មានរោគការអីដូចយើងពីដើម តែការទំលៀមទំលាប់យើងចេះឯងមានក្មេងខ្មែរមានអីដូចតែគ្នា ។

ប៊ុនថនៈ ចឹងដូចថានៅនេះមានសុវត្ថភាពមានសន្តិសុខអីហ្នឹងចាប់ពីពេលណាទៅចាប់ពីបោះឆ្នោត ហើយឬមួយយ៉ាងម៉េច?

ចំរើនៈ មានសន្តិភាពនិងសន្តិសុខចាប់ពីបោះឆ្នោត៩៣ហ្នឹងមកចេះតែស្រួលៗមករបូតចឹងមក ។

ប៊ុនថនៈ បាទ ។

ចំរើនៈ តាំងពី៩៣មកហ្នឹងចាប់ផ្តើមស្រួលរហូតហើយ ។

ប៊ុនថនៈ ចឹងពូនៅហ្នឹងរហូតអត់មានទៅណាទេ?

ចំរើនៈ ខ្ញុំនៅនេះរហូតអត់មានទៅណាទេ ។

ប៊ុនថនៈ ចឹងពូឈប់ធ្វើនេះហ្នឹងចាប់ពីបោះឆ្នោតនិងតែម្តង?

ចំរើនៈ បាទ!តាំងពីហ្នឹងមកឈប់និយាយទៅខ្ញុំឈប់តាំងពី៩៩ ។

ប៊ុនថនៈ ៩៩?

ចំរើនៈ មិនទាន់បោះឆ្នោត ។

ប៊ុនថនៈ ៩៩ពេលសមាហរណ៍កម្មហើយហ្នឹងពូ?

ចំរើនៈ មើល៨៩ ។

ប៊ុនថនៈ ៨៩?

ចំរើនៈ បាទ!៨៩ខ្ញុំចុះពីព្រំដែនមកខ្ញុំឈប់ធ្វើបណ្តោយតែឈ្មោះកងទ័ពនៅហ្នឹងឯងតែខ្ញុំឈប់ស៊ុយ ប្រវត្តិខ្លួនឯងបណ្តោយ ឈប់រកស៊ីខ្លួនឯងមិនបាច់ពីណាបង្ខំឲ្យឈប់ ។

ប៊ុនថនៈ ចឹងពូពិការហ្នឹងពូពិការដោយសារអីដែរ?

ចំរើនៈ ខ្ញុំពិការៗត្រូវគ្រាប់ ។

ប៊ុនថនៈ ពិការនៅពេលណាពូ?

ចំរើនៈ ខ្ញុំពិការឆ្នាំ៨៩ជិតចប់ហើយហ្នឹង ។

ប៊ុនថនៈ គ្រប់ខាងណាវិញពូ?

ចំរើនៈ ត្រូវគ្រាប់ខាងទាហានខាងក្នុងនេះ ។

ប៊ុនថនៈ បាញ់ត្រូវឬផ្ទោងត្រូវ?

ចំរើនៈ បាញ់គ្នានិងបណ្តោយជិតចប់ហើយ ។

ប៊ុនថនៈ ចឹងពិការហើយហ្នឹងបានពូមកនៅភូមិតែម្តង?

ចំរើនៈ បាទ!ពិការហើយអីហើយខ្ញុំទៅព្យាបាលដល់ខាវដាងអីម៉ាជាហើយបានខ្ញុំចុះពីព្រំដែនមកនៅផ្ទះតែម្តង ។

ប៊ុនថនៈ ចឹងពូការជាមួយគ្រួសារពីហើយបានពូបែកទៅទៀត?

ចំរើនៈ បាទ!បានគ្នាខ្ញុំនាំគ្រួសារខ្ញុំទៅនៅព្រំដែនតែម្តង អត់មានទុកនៅនេះទេ ។

ប៊ុនថនៈ បាទ!ចឹងចុះមកនៅហ្នឹងឆ្នាំ៨៩វិញ?

ចំរើនៈ ៨៩នាំកូនប្រពន្ធអីមកនៅ៨៩នេះ ។

ប៊ុនថនៈ ឥឡូវមានកូនប៉ុន្មាននាក់?

ចំរើនៈ ខ្ញុំមានកូនបួននាក់ ។

ប៊ុនថនៈ កូនបងគេធំហើយ?

ចំរើនៈ កូនបងគេមានប្រពន្ធហើយ ។

ប៊ុនថនៈ ចឹងបានគ្រួសារហើយ?

ចំរើនៈ បាទ!បានគ្រួសារហើយ ។

ប៊ុនថនៈ ចឹងពូនៅនេះមានស្គាល់តា ពិនអីទេ?

ចំរើនៈ តា ពិន បើនិយាយទៅគាត់មកនៅភូមិជើងនេះ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ គ្រាន់តែឃើញចឹងទៅស្គាល់និយាយរកនិយាយលេងចឹងឯងតែមិនដឹងយ៉ាងម៉េចអីយ៉ាងៗ មិនបានដឹងទេ ។

ប៊ុនថនៈ បាទ!តែមិនដែលទៅនិយាយជិតស្និតគ្រាន់តែទៅនិយាយលេងជារបៀបអ្នកភូមិ?

ចំរើនៈ បាទ!៩៩ហ្នឹងខ្ញុំចុះមកនៅមុនគាត់ ។

ប៊ុនថនៈ ៨៩?

ចំរើនៈ ៨៩ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ៨៩ហ្នឹងចុះមកនៅមុនគាត់ដល់នេះគាត់មកក្រោយទេ ។

ប៊ុនថនៈ គាត់នៅជំរំដែរពូ?

ចំរើនៈ បាទ!គាត់ចុះមកពីជំរំមកដែរ គាត់ចុះមកពីជំរំដងរែកនោះមកនៅផ្តាំនេះ ។

ប៊ុនថនៈ បាទ ។

ចំរើនៈ ខ្ញុំក៏នាំគ្នាអង្គុយនិយាយលេងជាមួយគាត់ធម្មតាចុះបើគាត់ចាស់ទុំ ។

ប៊ុនថន៖ បាទ ។

ចំរើន៖ យើងកូនក្មេងចេះនិយាយលេងធម្មតាចឹងទៅមិនដឹងថាគាត់យ៉ាងម៉េចអីយ៉ាងម៉េច ។

ប៊ុនថន៖ បាទ ។

ចំរើន៖ តែដឹងថាគាត់នៅជំរំខ្មែរក្រហមនោះហើយ ។

ប៊ុនថន៖ បាទ ។

ចំរើន៖ គ្រាន់តែដឹងប៉ុណ្ណោះឯងមិនថាគាត់របៀបម៉េចអីរបៀបម៉េចអីទេ ពីដើមមកមិនបានដឹងរលីង ។

ប៊ុនថន៖ បាទ!ចឹងទើបដឹងថាគាត់ជាប្រធានគុកអីហ្នឹងដឹងនៅពេលណា?

ចំរើន៖ ទើបដឹងនិងគេចាប់គាត់ហើយគេផ្សាយតាមវិទ្យុហ្នឹង ។

ប៊ុនថន៖ បាទ ។

ចំរើន៖ គេផ្សាយហើយដឹងថាកាត់ទោសអីហ្នឹងមើលតាមប៉ុស្តទូរទស្សន៍ហ្នឹង ។

ប៊ុនថន៖ ចឹងបានមើលដែរ?

ចំរើន៖ ខ្ញុំតាមដានមើលទាល់ចប់ បានដឹងថាតា ពិនឈ្មោះឌុចប្រធានគុកស-២១ហ្នឹងតើសើច..។

ប៊ុនថន៖ ពូជឿដែលដំបូងគេ ធ្លាប់ឃើញគាត់ផ្ទាល់?

ចំរើន៖ ឃើញផ្ទាល់និងឃើញចឹងជឿទាំងស្រុងតែម្តង ។

ប៊ុនថន៖ ជឿថាគាត់ចឹងទេ?

ចំរើន៖ ចុះបើនិយាយចឹងហើយបានជឿថា នៅនេះមិនដឹងថាតា ពិន ។

ប៊ុនថន៖ ចឹងពីមុនអ្នកភូមិមិនដឹងតែម្តងពូ?

ចំរើន៖ អត់ដឹងទាំងអស់អ្នកភូមិអត់មានដឹង គ្មានពីណាដឹង ដឹងថាគាត់ជាប្រជាជនធម្មតាដូចយើង ។

ប៊ុនថន៖ បាទ ។

ចំរើន៖ គាត់មករស់នៅនេះ ។

ប៊ុនថន៖ បាទ ។

ចំរើន៖ ចុងក្រោយមកបានប្រជាជនគេដឹងឮទាំងអស់ ។

ប៊ុនថន៖ បាទ ។

ចំរើន៖ ដឹងថាតា ពិន ជាប្រធានគុកប្រធានអីកាលសម័យប៉ុល ពត ។

ប៊ុនថន៖ បាទ ។

ចំរើន៖ ខ្ញុំក៏មិននឹកស្មាន ។

ប៊ុនថន៖ បាទ!ចឹងអត់នឹកស្មាន?

ចំរើន៖ អត់នឹកស្មានថា តា ពិនជាប្រធានគុកសម័យប៉ុល ពត ។

ប៊ុនថន៖ ចឹងពូមានអីចង់បន្ថែមទៀតទេ ដូចត្រូវការសួរដូចថាពូចង់ចាំអីចឹងណាស់?

ចំរើន៖ បាទ ។

ប៊ុនថន៖ ចង់បន្ថែមកន្លែងណាដែលពូចង់ចាំហើយពូចាប់អារម្មណ៍?

ចំរើន៖ អត់មានអីបន្ថែមទៀតទេ ។

ប៊ុនថន៖ បាទ!ចឹងខ្ញុំអរគុណពូច្រើន ។

ចំរើន៖ បាទ ។

**ចប់**